**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០១/២០០៣ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០០៣

**សូមជំរាបមក**

**ឯកឧត្តម ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**កម្មវត្ថុ** : ករណីសុំពន្យល់បញ្ជាក់អំពីចន្លោះច្បាប់នៃការប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងជំពូកទី៧ ស្តីពីការឃោសនាបោះឆ្នោត នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**យោង** : លិខិតលេខ ១២.១០៦/០២ គ.ជ.ប ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០២ របស់ឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ចំពោះសំណើដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញនាសម័យប្រជុំថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០០៣ បានពិនិត្យឃើញថាមានខុសនឹងនីតិវិធីដែលមានចង្អុលនៅក្នុងមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃព្រះរាជក្រម លេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាបស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ តាមមាត្រាទាំងនេះ ឯកឧត្តមដែលជាប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំអាចសុំផ្ទាល់ត្រង់មកក្រុមប្រឹក្សាធម្មនុញ្ញឱ្យបកស្រាយច្បាប់បានទេ ។

ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញពុំអាចទទួលសំណើរបស់ឯកឧត្តម ដើម្បីចេញសេចក្តីសម្រេចបកស្រាយខ្លឹមសារនៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានឡើយ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ហត្ថលេខា និង ត្រា**

**ប៊ិន ឈិន**